**កម្មវត្ថុ៖ ក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន – កិច្ចប្រជុំដោយផ្ទាល់និងតាមអនឡាញ – ថ្ងៃទី 30 ខែតុលា ឆ្នាំ 2025**

ភាគីពាក់ព័ន្ធយុត្តិធម៌បរិស្ថានទាំងអស់ជាទីគោរព!

ការិយាល័យប្រតិបត្តិកិច្ចការថាមពលនិងបរិស្ថាន (EEA) នឹងកោះអញ្ជើញក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន (EJC) ដើម្បីចូលរួមក្នុងកិច្ចប្រជុំបន្ទាប់របស់ខ្លួននៅ**ថ្ងៃទី 30 ខែតុលា ឆ្នាំ 2025 វេលាម៉ោង 6:30 ល្ងាច (ម៉ោងស្តង់ដាខាងកើត)**។ សមាជិកក្រុមប្រឹក្សានឹងពិភាក្សាអំពីបច្ចុប្បន្នភាពនៃកម្មវិធី Mass Save និង MassEnviroScreen។ ពេលវេលាកំណត់នៅក្នុងកិច្ចប្រជុំនឹងត្រូវបានផ្តល់ជូនសាធារណជនដើម្បីចែករំលែកមតិយោបល់។

**សូមចុះឈ្មោះសម្រាប់កិច្ចប្រជុំតាមរយៈតំណភ្ជាប់នេះ៖**
https://www.zoomgov.com/webinar/register/WN_Hv6CfVXhQNOR5CBNvqsG0g

**ការរៀបចំកិច្ចប្រជុំ៖** កិច្ចប្រជុំទម្រង់កូនកាត់នេះនឹងត្រូវបានរៀបចំឡើងទាំងតាមអនឡាញនៅលើ Zoom និងដោយផ្ទាល់នៅសាលប្រជុំរបស់សាលាក្រុង Leominster City Hall Auditorium។ កិច្ចប្រជុំនេះត្រូវបានប៉ាន់ស្មានថាមានរយៈពេល 90 នាទី។ អគារនេះមានទីតាំងស្ថិតនៅ 25 West St, Leominster, MA។ អាចធ្វើដំណើរទៅដល់តាមរយៈរថភ្លើង Commuter Rail ដោយខ្សែ Fitchburg Line ចុះនៅស្ថានីយ North Leominster Station និងឡើងបន្តដោយឡានក្រុង MART ខ្សែលេខ 3។ កន្លែងចតរថយន្តមាននៅក្នុងចំណតរបស់សាលប្រជុំ Leominster City Hall Auditorium។

**ជំនួយផ្នែកបកប្រែ៖** ការបកប្រែផ្ទាល់មាត់តាមអនឡាញនឹងរួមមាន ភាសាអេស្ប៉ាញ ព័រទុយហ្គាល់ ចិនកុកងឺ វៀតណាម ក្រេអូលហៃទី និងភាសាសញ្ញាអាមេរិក (ASL)។ ប្រសិនបើអ្នកត្រូវការការបកប្រែផ្ទាល់មាត់ជាភាសាជាក់លាក់ ឬការសម្របសម្រួលណាមួយបន្ថែម សូមបញ្ជូលសំណើនោះក្នុងអ៊ីមែលទៅកាន់ meetings@erg.com។ សំណើត្រូវតែដាក់ជូនរយៈពេល 48 ម៉ោងមុនពេលកិច្ចប្រជុំចាប់ផ្តើម។
ដើម្បីទទួលបានព័ត៌មាននេះជាភាសាអង់គ្លេសអក្សរពុម្ពធំ ឬអក្សរស្ទាបសម្រាប់មនុស្សពិការភ្នែក សូមហៅទូរសព្ទទៅលេខ 1-877-623-6765។ TTY៖ 1877-623-7773។

**ច្បាប់ប្រជុំដោយបើកចំហ៖** ក្រុមប្រឹក្សា EJ ប្រតិបត្តិការក្រោមច្បាប់ប្រជុំដោយបើកចំហ [https://www.mass.gov/the-open-meeting-law] ហើយស្វាគមន៍សមាជិកសាធារណជនទាំងអស់ដែលមានបំណងចង់ចូលរួមសង្កេតកិច្ចប្រជុំបើកចំហរបស់ខ្លួន។ ក្នុងអំឡុងពេលប្រជុំនេះ អ្នកសង្កេតការណ៍អាចបញ្ចេញមតិ ឬសួរទៅក្រុមប្រឹក្សា EJ ដោយមានការអនុញ្ញាតពីប្រធានអង្គប្រជុំ។

**ព័ត៌មានបន្ថែមអំពីក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន (EJC)៖** EJC ត្រូវបានតែងតាំងដោយអភិបាលដើម្បីផ្តល់យោបល់ និងផ្តល់អនុសាសន៍ដល់រដ្ឋមន្ត្រី EEA អំពីគោលនយោបាយ និងស្តង់ដាដែលពាក់ព័ន្ធ ដើម្បីសម្រេចបាននូវគោលការណ៍យុត្តិធម៌បរិស្ថាននានា។ គោលការណ៍ទាំងនេះត្រូវបានកំណត់ដោយច្បាប់របស់រដ្ឋថាជា “គោលការណ៍ដែលគាំទ្រការការពារពីការបំពុលបរិស្ថាន និងសមត្ថភាពក្នុងការរស់នៅក្នុងបរិស្ថានស្អាត និងមានសុខភាពល្អ ដោយមិនគិតពីពូជសាសន៍ ពណ៌សម្បុរ ប្រាក់ចំណូល វណ្ណៈ ពិការភាព អត្តសញ្ញាណយេនឌ័រ ទំនោរផ្លូវភេទ ដើមកំណើតជាតិ ជាតិសាសន៍ ឬពូជពង្ស ជំនឿសាសនា ឬជំនាញភាសាអង់គ្លេស ដែលរួមមាន៖ (i) ការចូលរួមយ៉ាងសកម្មរបស់ប្រជាជនទាំងអស់ពាក់ព័ន្ធនឹងការអភិវឌ្ឍ ការអនុវត្ត និងការពង្រឹងការអនុវត្តច្បាប់ បទបញ្ញត្តិ និងគោលនយោបាយបរិស្ថាន ដោយរួមទាំងគោលនយោបាយស្តីពីបម្រែបម្រួលអាកាសធាតុ និង (ii) បំណែងចែកប្រកបដោយសមធម៌នូវថាមពលនិងផលប្រយោជន៍បរិស្ថាន ព្រមទាំងបន្ទុកបរិស្ថាន។” ច្បាប់នេះត្រូវបានចែងត្រង់

ផ្នែក 62L ក្នុងតំណនេះ៖
[https://malegislature.gov/Laws/SessionLaws/Acts/2021/Chapter8]។

ព័ត៌មានបន្ថែមអំពី EJC របៀបវារៈនៃកិច្ចប្រជុំនាពេលខាងមុខ និងរបាយការណ៍កិច្ចប្រជុំកន្លងមក អាចរកបាននៅទីនេះ៖ https://www.mass.gov/orgs/environmental-justice-council។ សូមចុចលើពាក្យ “Select Language” នៅខាងលើផ្នែកខាងស្ដាំនៃគេហទំព័រ ដើម្បីបកប្រែទំព័រនេះ។

សូមអរគុណ!

María Belén Power
អនុរដ្ឋមន្ត្រីសមធម៌និងយុត្តិធម៌បរិស្ថាន
ការិយាល័យប្រតិបត្តិកិច្ចការថាមពលនិងបរិស្ថាន